ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**កំពង់ផែស្វយ័តក្រុងព្រះសីហនុ**

លេខ: ០៧១ សជណ/កសស/រប.ធម

ថ្ងៃ ចន្ទ ១៤ រោច ខែ ពិសាខ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស ២៥៦៥
ខេត្តព្រះសីហនុ ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០២១

# សេចក្ដីជូនដំណឹង

## ស្ដីពី

## កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក លើកទី៤ របស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ

**កំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស)** មានកិត្តិយសសូមគោរពជម្រាបជូនដំណឹងដល់ភាគហ៊ុនិក ដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតប្រភេទ "ខ" និងប្រភេទ "គ" របស់ **កសស** ទាំងអស់មេត្តាជ្រាបថា ៖ **កសស** នឹងរៀបចំការប្រជុំមហាសន្និបាតភាគហ៊ុនិកលើកទី៤ តាមការកំណត់ដូចខាងក្រោម ៖

១. កាលបរិច្ឆេទកំណត់ទុក (Record Date) ៖ **ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០២១**

២. កាលបរិច្ឆេទ មហាសន្និបាតភាគហ៊ុនិកលើកទី៤ ៖ **ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០២១**

៣. ទីកន្លែងប្រារព្ធពិធី មហាសន្និបាតភាគហ៊ុនិកលើកទី៤ ៖
- សណ្ឋាគារ សុខា ប៊ិច រីសត , ខេត្តព្រះសីហនុ ជាមួយនឹងប្រព័ន្ធវីដេអូខល តាមកម្មវិធី ZOOM ( ទៅតាមស្ថានភាពជាក់ស្ដែង )

៤. របៀបវារៈនៃការប្រជុំមហាសន្និបាតភាគហ៊ុនិក លើកទី៤ របស់ **កសស** មានដូចខាងក្រោម ៖
- ម៉ោង ០៧:០០ - ០៧:៤៥ ៖ ការចុះវត្តមានអ្នកចូលរួម
- ម៉ោង ០៧:៤៥ - ០៨:០០ ៖ គណៈអធិបតី អញ្ជើញមកដល់
- ម៉ោង ០៨:១០ - ០៨:៣០ ៖ ប្រកាសសមាសភាពគណៈអធិបតី និងគោរពភ្លេងជាតិ
- ម៉ោង ០៨:៣០ - ០៩:០០ ៖ មតិស្វាគមន៍របស់ ប្រធានមហាសន្និបាត
- ម៉ោង ០៩:០០ - ១០:០០ ៖
  - សំណើសុំពិនិត្យ និងអនុម័ត បែងចែកភាគលាភជូនភាគហ៊ុនិកសម្រាប់ឆ្នាំ២០២០ និងប្រាក់លាភការសម្រាប់ក្រុមប្រឹក្សាភិបាល អាណត្តិទី៨ និងមន្ត្រីត្រួតពិនិត្យរដ្ឋ
  - ការបោះឆ្នោតជ្រើសតាំង អភិបាលឯករាជ្យ
  - ការបោះឆ្នោតជ្រើសតាំង អភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន
- ម៉ោង ១០:០០ - ១១:០០ ៖
  - បទបង្ហាញស្ដីពីលទ្ធផលការងារអាជីវកម្ម-សេវាកម្ម ឆ្នាំ២០២០ និងទិសដៅអនុវត្តការងារ ឆ្នាំ២០២១
  - សំណួរ និងចម្លើយ
  - ប្រកាសលទ្ធផលការបោះឆ្នោត និងមតិបិទកម្មវិធី ។

តិរវិថី សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
Tarak Vithei Samdech Akka Moha Sena Padei Techo HUN SEN
Sangkat N°3, Preah Sihanouk City, Preah Sihanouk Province
Office : 034 933 416; 034 933 511 Pilot : 034 933 507; Fax : 034 933 693
E-mail : pasinfo@pas.gov.kh; spsez@pas.gov.kh
Website: www.pas.gov.kh

ភាគហ៊ុនិកដែលមានឈ្មោះក្នុងបញ្ជីឈ្មោះភាគហ៊ុនិកនាថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០២១ (កាលបរិច្ឆេទកំណត់ទុក) នឹងទទួលបានលិខិតអញ្ជើញ តាមរយៈសារអេឡិចត្រូនិកពី ធនាគារ អេស៊ីលីដា ភីអិលស៊ី (ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ របស់ **កសស**) ឬអាចស្នើសុំមក **កសស** តាមរយៈលេខទូរស័ព្ទទំនាក់ទំនងដូចមានភ្ជាប់មកជាមួយ **ចាប់ពីថ្ងៃទី ១១ ដល់ ២៥ ខែ មិថុនា ឆ្នាំ ២០២១** ។

បន្ទាប់ពីទទួលបានលិខិតអញ្ជើញតាមរយៈការជូនដំណឹងខាងលើ សូមភាគហ៊ុនិក មេត្តាទៅបញ្ជាក់ការចូលរួមនៅ ធនាគារ អេស៊ីលីដា ភីអិលស៊ី (ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ របស់ **កសស**) ឬ កំពង់ផែស្វយ័តក្រុងព្រះសីហនុ តាមរយៈការជូនដំណឹងស្របតាមស្ថានភាពអនុវត្តជាក់ស្តែង ឬ តាមរយៈតំណភ្ជាប់ ( Link ) របស់ **កសស** ក៏ដូចជា QR Code របស់ប្រព័ន្ធចុះវត្តមាន និងបោះឆ្នោត ( Registration and Voting System ) ដែល **កសស** បានផ្តល់ជូននៅលើលិខិតអញ្ជើញតាមរយៈសារអេឡិចត្រូនិក **ចាប់ពីថ្ងៃទី ១១ ដល់ ២៥ ខែ មិថុនា ឆ្នាំ ២០២១** ។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមក កំពង់ផែស្វយ័តក្រុងព្រះសីហនុ និង ធនាគារ អេស៊ីលីដា ភីអិលស៊ី តាមអាសយដ្ឋាន និងលេខទូរស័ព្ទទំនាក់ទំនង ដូចខាងក្រោម ៖

**១. កំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស)**

- អាសយដ្ឋាន: តិរវិថីសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន, សង្កាត់លេខ ៣, ក្រុង-ខេត្តព្រះសីហនុ
- ទូរស័ព្ទ: (៨៥៥) ១០ ៧៨៨ ៨៨០ / ៩៥ ៦៦៨ ៨៩៧ / ១១ ៨១៧ ៨៤៧
- សារអេឡិចត្រូនិច: pasinfo@pas.gov.kh
- គេហទំព័រ: www.pas.gov.kh

**២. ធនាគារ អេស៊ីលីដា ភីអិលស៊ី**

- អាសយដ្ឋាន: លេខ ៦១, មហាវិថីព្រះមុនីវង្ស, សង្កាត់ស្រះចក, ខណ្ឌដូនពេញ, រាជធានីភ្នំពេញ
- ទូរស័ព្ទ: (៨៥៥) ២៣ ៩៩៨ ៧៧៧ (ភ្ជាប់ទៅ: ០៥០១៣)
  - **លោក លីម អាន** ប្រធានផ្នែកប្រតិបត្តិការ RTP
  - លេខទូរស័ព្ទ: (៨៥៥) ១៥ ៦០០ ៧៤៣ / ៧៧ ៥៦៧ ៩៣៥
  - សារអេឡិចត្រូនិច: lim.an@acledabank.com.kh , lim.phengan@gmail.com
  - **លោក ហួត សុភី** អនុប្រធានផ្នែកប្រតិបត្តិការ RTP
  - លេខទូរស័ព្ទ: (៨៥៥) ១៥ ៩០០ ៥៣៨
  - សារអេឡិចត្រូនិច: huot.sophy@acledabank.com.kh
  - **លោកស្រី សំរិទ្ធ វណ្ណីបុប្ផារដ្ឋ** បុគ្គលិកផ្នែកប្រតិបត្តិការ RTP
  - លេខទូរស័ព្ទ: (៨៥៥) ៨១ ៦៨៦ ៩៨៨ / ៦១ ២៨៧ ៧៦៦
  - សារអេឡិចត្រូនិច: op.rtp@acledabank.com.kh

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**
**ទទួលបន្ទុកជាប្រធានអគ្គនាយក**

**លូ_គឹមឈន់**

**ចម្លងជូន៖**
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- គណៈកម្មការមូលបត្រកម្ពុជា
- ក្រុមប្រឹក្សាភិបាល កសស

"ដើម្បីជូនជ្រាប"
- ផ្សារមូលបត្រកម្ពុជា និង ក្រុមហ៊ុនមូលបត្រ

"ដើម្បីជូនផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ